ក **N°58/16** *08/8/2016*

# មាតិកា

## I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ


២៨-៧-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៤៤ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ព្រះសង្ឃ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងកញ្ញា ចំនួន ២៥៤ អង្គ/រូប ៦៧៦៧

២៨-៧-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៤៥ ស្តីពី ការតែងតាំង និងផ្តល់ឋានៈទីប្រឹក្សា ឯកឧត្តម **អ៊ុំ ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ០២ រូប ៦៧៧១

២៨-៧-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៧១៦/៧៤៦ ស្តីពី ការបញ្ចប់មុខតំណែងឯកឧត្តម **ហេង រតនា** ពីជំនួយការសម្តេចព្រះមហិស្សរា **នរោត្តម ចក្រពង្ស** តែងតាំង និងផ្តល់ឋានៈឯកឧត្តម **ឡើក សុថាវិន** ជាជំនួយការសម្តេចព្រះមហិស្សរា **នរោត្តម ចក្រពង្ស** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ អគ្គនាយក ៦៧៧២

០៦-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៤៧ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា ចំពោះ Mr. Zhan Jin Sheng និង Mr. Xiao Xinming ៦៧៧៣

០៦-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៤៨ ស្តីពី ការតែងតាំង និងផ្តល់ឋានៈអនុប្រធាន និងសមាជិក នៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ចំនួន ០៣ រូប ៦៧៧៤

០៦-៨-២០១៦ -ព្រះរាជក្រឹត្យ នស/រកត/០៨១៦/៧៤៩ ស្តីពី ការតែងតាំង និងផ្តល់ឋានៈ ដល់លោកវេជ្ជបណ្ឌិតឯកទេស **ហ៊ុន ចំរើន** ជាសាស្ត្រាចារ្យមហាបរិញ្ញា នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ៦៧៧៥


## II.រាជរដ្ឋាភិបាល

## ១.អនុក្រឹត្យ


០២-៨-២០១៦ -អនុក្រឹត្យលេខ ១៦១ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ៦ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ៦៧៧៦

០៨-៨-២០១៦ -អនុក្រឹត្យលេខ ១៦២ អនក្រ.បក ស្តីពី គ្រូពុទ្ធិកសិក្សា និងមន្ត្រីបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ៦៧៧៩

១១-៨-២០១៦ - អនុក្រឹត្យលេខ ១៦៣ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៦៧៨៥

០២-៨-២០១៦ -អនុក្រឹត្យលេខ ៨៤០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៦៧៨៧

០២-៨-២០១៦ -អនុក្រឹត្យលេខ ៨៤១ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៦៧៨៨

០៨-៨-២០១៦ -អនុក្រឹត្យលេខ ៨៤២ អនក្រ.តត ស្តីពី ការតែងតាំងទីប្រឹក្សាពាណិជ្ជកម្ម ៦៧៨៩

០៨-៨-២០១៦ -អនុក្រឹត្យលេខ ៨៤៣ អនក្រ.តត ស្តីពី ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា ៦៧៩១

០៩-៨-២០១៦ -អនុក្រឹត្យលេខ ៨៤៤ អនក្រ.តត ស្តីពី ការប្តូរ និងតំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ៦៧៩២

០៩-៨-២០១៦ -អនុក្រឹត្យលេខ ៨៤៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៦៧៩៣

០៩-៨-២០១៦ -អនុក្រឹត្យលេខ ៨៤៦ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍ ៦៧៩៤

០៩-៨-២០១៦ -អនុក្រឹត្យលេខ ៨៤៧ អនក្រ.តត ស្តីពី ការតម្លើងថ្នាក់ ឋានន្តរស័ក្តិ និងនិយ័តកម្មថ្នាក់មន្ត្រីរាជការ ៦៧៩៩

០៩-៨-២០១៦ -អនុក្រឹត្យលេខ ៨៤៨ អនក្រ.តត ស្តីពី ការតែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការ ៦៨០៥


## ២_សេចក្តីសម្រេច


០២-៨-២០១៦ -សេចក្តីសម្រេចលេខ ៧៧ សសរ ស្តីពី ការតែងតាំងប្រធានក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៦៨០៧

០២-៨-២០១៦ -សេចក្តីសម្រេចលេខ ៧៨ សសរ ស្តីពី ការតែងតាំងប្រធានក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៦៨០៩

០២-៨-២០១៦ -សេចក្តីសម្រេចលេខ ៧៩ សសរ ស្តីពី ការតែងតាំងអនុប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាលកម្ពុជា ៦៨១១

០២-៨-២០១៦ -សេចក្តីសម្រេចលេខ ៨០ សសរ ស្តីពី ការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងសម្រាប់គាំទ្រគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងសាកល "Global Deal Initiative" ៦៨១៣

០៣-៨-២០១៦ -សេចក្តីសម្រេចលេខ ៨១ សសរ ស្តីពី ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជននៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៨ ៦៨១៥

### ៣-សារាចរ

១៥-៨-២០១៦ -សារាចរលេខ ០៨ សរ ស្តីពី ការគ្រប់គ្រងផ្សារគ្រប់ប្រភេទនៅទូទាំងប្រទេស ៦៨១៧

## III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០១-៧-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៧៥៧ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៦៨២០

១៣-៧-២០១៦ -ប្រកាសលេខ ៨៥១ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងរជ្ជទេយ្យករបុរេប្រទានរង របស់អគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៦៨២៣

១៨-៧-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៨៦១ សហវ.ប្រក ស្តីពី ការបង្កើតរជ្ជទេយ្យចំណូល របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៦៨២៦

១៨-៧-២០១៦ -ប្រកាសអន្តរក្រសួងលេខ ៨៦២ សហវ.ប្រក ស្តីពី ការតែងតាំងរជ្ជទេយ្យករចំណូល និងរជ្ជទេយ្យករចំណូលរង របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ៦៨២៨

### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

២៥-៧-២០១៦ -ប្រកាសអន្តរក្រសួងលេខ ២៩១ ក.ប/ប្រក ស្តីពី កិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាល រវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខា ភិបាល សម្រាប់ផ្នែកថែទាំសុខភាព ៦៨៣០

### ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម

២៤-៣-២០១៦ -ប្រកាសលេខ ២០២ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន គូឡាវ៉ា វ៉ាធើ បង្កើតរោងចក្រ ផលិតទឹកបរិសុទ្ធ ៦៨៦៣

២៤-៣-២០១៦ -ប្រកាសលេខ ២០៣ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេមផាយ អង្គរ អ៊ីមផត & អិចផត បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៦៨៦៦

២៥-៣-២០១៦ -ប្រកាសលេខ ២០៤ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេស៊ា សេនត្រល ប្រាយម៍ រ៉ាយស៍ ខមភេនី លីមីធីត បង្កើតរោងម៉ាស៊ីន កិនស្រូវ ៦៨៦៩

២៥-៣-២០១៦ -ប្រកាសលេខ ២០៥ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហាណា ម៉ាយក្រូអេឡិចត្រូនិក (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្ភារៈបរិក្ខារអេឡិចត្រូនិក ៦៨៧២
២៥-៣-២០១៦ -ប្រកាសលេខ ២០៦ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អេ អេន ជេ (ខេមបូឌា) បង្កើតរោងចក្រ តម្លើងទោចក្រយាន (កង់) ៦៨៧៥
២៥-៣-២០១៦ -ប្រកាសលេខ ២០៧ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ា ឡុង (ខេមបូឌា) អៅសូល អ៊ិនដាសស្ត្រី បង្កើតរោងចក្រ ផលិតស្បែកជើង និងគ្រឿងបន្ទុំស្បែកជើង ៦៨៧៨
២៥-៣-២០១៦ -ប្រកាសលេខ ២០៨ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឈឹង យៀ អ៊ិនធើប្រាយ បង្កើតរោងចក្រ ផលិតគ្រឿងបន្ទុំស្បែកជើង ៦៨៨១
២៥-៣-២០១៦ -ប្រកាសលេខ ២០៩ ឧស.កឧ.ប្រក.០៣ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ូន-វេស្ត (ខេមបូឌា) បង្កើតរោងចក្រ តម្លើងសម្ភារៈបរិក្ខារអគ្គិសនី ៦៨៨៤

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៤៨

យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( យោងតាមសេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចវិបុលសេនាភក្ដី **សាយ ឈុំ**
ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦ )

## ត្រាស់ព្រះរាជឱង្ការ

## ឱ្យ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- លោកស្រីឧត្ដមសេនីយ៍ត្រី **ទី សាឌី**
២- លោកឧត្ដមសេនីយ៍ត្រី **ឡុង ស្រេង**
៣- លោកឧត្ដមសេនីយ៍ត្រី **នួន សុវណ្ណារ៉ា**
៤- លោកជំទាវ **គុជ ច័ន្ទម៉ាឡា**
៥- លោកជំទាវ **សួរ ឆារី**
៦- លោកឧសភការីឧត្ដម **យាន អ៊ុំស្រេង**
៧- លោក **ពុធ សុខា**
៨- លោក **ជួប ចំរើន**
៩- លោក **វុត្ថ ផារា**
១០- លោកស្រី **ទន ថារី**
១១- លោក **កែវ ហុងលី**
១២- លោក **គីម វិសាល**
១៣- លោក **ទុយ សាវី**
១៤- លោក **វិជ្ជា វឌ្ឍនា**
១៥- លោក **ស៊ុំ សុគន្ធរដ្ឋា**
១៦- លោក **វុត្ថ ចន្ថា**
១៧- លោក **មៀន បូរី**
១៨- លោក **ឡុង សំណាង**
១៩- លោក **តឹក ទុត្ថា**
២០- លោក **សុខ ជាវិត**
២១- លោក **សុខ ជាវី**
២២- លោក **ឆាយ សុវណ្ណ**
៣៦- លោក **កៀង លីក្ស**
៣៧- លោក **ឈួន សំណាង**
៣៨- លោក **ញ៉ាញ់ ហាន**
៣៩- លោក **ចុល ចេត**
៤០- លោក **ពៅ រិទ្ធី**
៤១- លោក **លឹម សេងលី**
៤២- លោក **តា ដេខ្មៀន**
៤៣- លោក **ប៊ុំ បូណា**
៤៤- លោក **អាន សំអាត**
៤៥- លោកស្រី **ខេង នេងលីម**
៤៦- លោក **មាស រ៉ាវុធ**
៤៧- លោក **យៀត គិន**
៤៨- លោក **ថេង រ៉ាមី**
៤៩- លោក **មាស ចន្ទពិសិដ្ឋ**
៥០- លោក **ហ៊ុយ សុខហាក់**
៥១- លោក **ខឹម ណារ៉ូ**
៥២- លោក **សេង សុវឌ្ឍនា**
៥៣- លោក **ប៉ាវ សុម្ភត**
៥៤- លោក **សុក ចំរើន**
៥៥- លោក **ឡុង វិចិត្រ**
៥៦- លោក **ជី វិសាល**
៥៧- លោក **មៀង សារិទ្ធ**

ROYAUME DU CAMBODGE
ព្រះរាជវាំង
LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ២៣- លោក | **សខ សុខឡុនា** | ៥៨- លោក | **ហ៊ឹម យ៉ាន** |
| ២៤- លោក | **គូ ស្រី** | ៥៩- លោក | **ស៊ុន សុភី** |
| ២៥- លោក | **នួន សារ៉ុន** | ៦០- លោក | **យ៉េម សារិទ្ធ** |
| ២៦- លោក | **លី តិរុណា** | ៦១- លោក | **ហែន ពុជ** |
| ២៧- លោក | **ឆន ដារ៉ា** | ៦២- លោក | **នួន សានី** |
| ២៨- លោក | **ស៊ី សុគន្ធា** | ៦៣- លោក | **អ៊ែ សំអាន** |
| ២៩- លោក | **គ្រួច បូរិទ្ធ** | ៦៤- លោក | **ប៊ុន សុផា** |
| ៣០- លោក | **សុខ ខៀន** | ៦៥- លោក | **យស សុខេមរ័ត្ននា** |
| ៣១- លោក | **ជា សុខរង្សី** | ៦៦- លោក | **លឹម គីមអាង** |
| ៣២- លោក | **ម៉ាន សុផាន់ណា** | ៦៧- លោក | **ម៉ៅ ពិសិដ្ឋ** |
| ៣៣- លោក | **ម៉េង ពៅវិសាល** | ៦៨- លោក | **លី ដាឡាន** |
| ៣៤- លោក | **ខាត់ ណារិទ្ធ** | ៦៩- លោកស្រី | **អ៊ូ វាសនា** |
| ៣៥- លោក | **សួរ ខែមវីរៈ** | ៧០- លោក | **សេង ថាវរិន** |

ខ- គ្រឿងឥស្សរិយយស **សម្តេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

| | | | |
|---|---|---|---|
| ១- លោកជំទាវវេជ្ជបណ្ឌិត | **សុខា សុធានី** | ៣- លោក | **ចាន់ អូន** |
| ២- លោកជំទាវ | **នន់ ប៊ុណ្ណា** | ៤- លោក | **គួន គូម៉ូនីរតន៍** |

គ- គ្រឿងឥស្សរិយយស **មុន្នីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

| | | | |
|---|---|---|---|
| ១- លោកឧត្តមសេនីយ៍ទោ | **ឆាយ នាង** | ៦- លោក | **ឌូច យុន្ធា** |
| ២- លោកវេជ្ជបណ្ឌិត | **អ៊ុយ ឈួង** | ៧- លោក | **ឥន យឿន** |
| ៣- លោក | **ចឹយ វិចិត្ត** | ៨- លោក | **ឌូច ពិនតារា** |
| ៤- លោក | **ចាន់ វិចិត្រ** | ៩- លោក | **ស្រ៊ុន សណ្តាប់** |
| ៥- លោក | **សុខ ប៊ុនចាន់** | ១០- លោក | **ម៉ាន សំអាត** |

ឃ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍ :**

| | | | |
|---|---|---|---|
| ១- ឧត្តមសេនីយ៍ទោ | **ឆន វិមានច័ន្ទ** | ៤- លោក | **លី សុខគួង** |
| ២- លោកវេជ្ជបណ្ឌិត | **ង្វៀន ហាច** | ៥- លោក | **នួន ដាញ៉ិល** |
| ៣- លោក | **ឌុយ ប៊ុនសេរីរត្នមុនី** | ៦- លោក | **ពៅ សេងហួរ** |

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា :**

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ហួន សារឿន** | ៣១- លោក | **ទី សារ៉ន** |
| ២- ឯកឧត្តម | **សេង ឡុត** | ៣២- លោក | **ប៉ាន់ ឫស្ស** |
| ៣- ឯកឧត្តម | **ប៉ែន ច័ន្ទសុខខេមរា** | ៣៣- លោក | **គង់ សោភ័ណ្ឌតារារម្យ** |
| ៤- លោកវេជ្ជបណ្ឌិត | **ប៊ុល សៀង** | ៣៤- លោក | **ចៅ ភីរម្យ** |
| ៥- លោកវេជ្ជបណ្ឌិត | **ថៃ ប៊ីឡៀន** | ៣៥- លោក | **កែវ ឧត្តម** |
| ៦- លោកវេជ្ជបណ្ឌិត | **រឹម វាសនា** | ៣៦- លោក | **ផុន សំបូរ** |
| ៧- លោកស្រីវេជ្ជបណ្ឌិត | **ម៉េង សុខលី** | ៣៧- លោកស្រី | **Akiko SASAKI** |
| ៨- លោកវេជ្ជបណ្ឌិត | **សាន ចំរើនរិទ្ធ** | ៣៨- លោក | **គីត ទុត្ថា** |
| ៩- លោកវរសេនីយ៍ឯក | **ពូ ដាវី** | ៣៩- លោក | **តេង សុភា** |
| ១០- លោក | **ជិន ដា** | ៤០- លោក | **លឹម សូទៀត** |
| ១១- លោកវេជ្ជបណ្ឌិត | **ប៊ុង បូរ៉ា** | ៤១- លោក | **ខៀវ រិនឫទ្ធិ** |
| ១២- លោកវេជ្ជបណ្ឌិត | **ជឹក ថាវង្ស** | ៤២- លោក | **ឡុង គញ្ញារិទ្ធ** |
| ១៣- លោកវេជ្ជបណ្ឌិត | **សាំង មករា** | ៤៣- លោក | **លឹម ម៉េងអាន** |
| ១៤- លោកវេជ្ជបណ្ឌិត | **យឹង វន** | ៤៤- លោក | **ឡុង ចាន់វាសនា** |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ១៥- លោកវេជ្ជបណ្ឌិត | ញ៉ាំ សន្ធន | ៤៥- លោក | ស៊ុយ គីមសាន |
| ១៦- លោកវេជ្ជបណ្ឌិត | អៀង ណារ៉ែត | ៤៦- លោក | ហោរ ទាសនា |
| ១៧- លោកវេជ្ជបណ្ឌិត | អ៊ិន សុខឡារ៉ា | ៤៧- លោក | អ៊ុំ ម៉ុនធឿន |
| ១៨- លោកវេជ្ជបណ្ឌិត | ឃី ស្រេង | ៤៨- លោក | ជួន ធី |
| ១៩- លោកវេជ្ជបណ្ឌិត | យ៉ាំង សារ៉េត | ៤៩- លោក | Koji SASAKI |
| ២០- លោកវេជ្ជបណ្ឌិត | អៀ ខួន | ៥០- លោក | យស ពុទ្ធីរ៉ាត់ |
| ២១- លោក | ឌី ទេពកោសល្យ | ៥១- លោក | នង ម៉ុនហេង |
| ២២- លោក | ហួត ស៊ាងហៃ | ៥២- លោក | ឆាយ សុខលី |
| ២៣- លោក | ញៀម គោ | ៥៣- លោក | លីម ចាន់ថា |
| ២៤- លោក | លៀង សម្ភោគ | ៥៤- លោក | គុយ សេដា |
| ២៥- លោក | ហ៊ិត ម៉ាន់ធី | ៥៥- លោក | ថូម ឈុនហាក់ |
| ២៦- លោក | ជា សុធារ៉ា | ៥៦- លោក | នង គីមឡេង |
| ២៧- លោក | កែត ស៊ុំវិនី | ៥៧- លោក | ម៉ប់ សារ៉េត |
| ២៨- លោក | ណុប វណ្ណា | ៥៨- លោក | គ្រួច សុធន |
| ២៩- លោក | ម៉ុំ លីមហួរ | ៥៩- លោក | សំ ជនិត |
| ៣០- លោក | ម៉ាន់ រួន | ៦០- លោក | ប៉ែន ធឿន |

ច- គ្រឿងឥស្សរិយយស **សម្ដេចព្រះមហាក្សត្រីយានី ព្រះស៊ីសុវត្ថិមុនីវង្ស កុសុមៈនារីរ័ត្ន** ថ្នាក់ **មហាសេនា :**

| | | | |
|---|---|---|---|
| ១- លោកស្រីវេជ្ជបណ្ឌិត | សុខ សុខេម | ៣- លោកស្រីវេជ្ជបណ្ឌិត | ឡៀប ពិណេណ |
| ២- លោកស្រីវេជ្ជបណ្ឌិត | លឹម ពៅ | ៤- កញ្ញា | ពុត ឡៃហេង |

ឆ- គ្រឿងឥស្សរិយយស **មុន្នីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា :**

| | | | |
|---|---|---|---|
| ១- លោកវេជ្ជបណ្ឌិត | យូ ពិសិដ្ឋ | ១១- លោកវេជ្ជបណ្ឌិត | ឈុន ឡាយ |
| ២- លោកវេជ្ជបណ្ឌិត | ហេង ច្រាង | ១២- លោកវេជ្ជបណ្ឌិត | អំណាត់ តក្កី |
| ៣- លោកសាស្ត្រាចារ្យ | ជុំ មុនីដារិន | ១៣- លោកវេជ្ជបណ្ឌិត | ហេង ហួរ |
| ៤- លោកវេជ្ជបណ្ឌិត | សៅ សុគន្ធវឡ្យនា | ១៤- លោកទន្តបណ្ឌិត | សារុន សារាមុនី |
| ៥- លោកវេជ្ជបណ្ឌិត | ជា យុទ្ធារុណ | ១៥- លោកវេជ្ជបណ្ឌិត | ហេង លី |
| ៦- លោកទន្តបណ្ឌិត | កែវ ឱណាម៉ូរ៉ា | ១៦- លោកវេជ្ជបណ្ឌិត | ជ តុនី |
| ៧- លោកវេជ្ជបណ្ឌិត | ហម ឡុង | ១៧- លោកវេជ្ជបណ្ឌិត | សំ ប៊ុរិន |
| ៨- លោកវេជ្ជបណ្ឌិត | ជិន កែវសុវណ្ណ | ១៨- លោកវេជ្ជបណ្ឌិត | ឡេង វិណ្ណា |
| ៩- លោកវេជ្ជបណ្ឌិត | កែវ វិបុល | ១៩- លោក | ឌុន រ៉ាឌី |
| ១០- លោក | ឃុន ឌី | ២០- លោក | ស៊ិន រ៉ុត |

ជ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា :**

| | | | |
|---|---|---|---|
| ១- លោក | ទី វុត្ថា | ២- លោក | ផាន់ សុផល |

ឈ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ :**

| | | | |
|---|---|---|---|
| ១- លោកវេជ្ជបណ្ឌិត | យឹម ដេត | ២០- លោកទន្តបណ្ឌិត | សៅ សុភាពរ៉ា |
| ២- លោកស្រីទន្តបណ្ឌិត | ឡាយ រ៉ាវី | ២១- លោកទន្តបណ្ឌិត | គួច បុភា |
| ៣- លោកទន្តបណ្ឌិត | ម៉ុន គីមឆៅ | ២២- លោកទន្តបណ្ឌិត | ឈួយ គីមឆុន |
| ៤- លោកទន្តបណ្ឌិត | ឆន មករា | ២៣- លោក | ញ៉ូវ សុវណ្ណធា |
| ៥- លោកវេជ្ជបណ្ឌិត | ម៉ុនធុន រិទ្ធីយ៉ា | ២៤- លោកវេជ្ជបណ្ឌិត | ហេង ចំរើន |
| ៦- លោកវេជ្ជបណ្ឌិត | ជុំ ចំនួនវិច្ឆិកា | ២៥- លោកវេជ្ជបណ្ឌិត | អ៊ុំ ម៉ុនធឿន |
| ៧- លោកវេជ្ជបណ្ឌិត | ឆាង បញ្ញាវុឌ្ឍី | ២៦- លោកវេជ្ជបណ្ឌិត | ស្ដើង អឿស |
| ៨- លោកវេជ្ជបណ្ឌិត | បាល់ សុភ័ក្រ | ២៧- លោកវេជ្ជបណ្ឌិត | លួន ទូច |
| ៩- លោកវេជ្ជបណ្ឌិត | ចារ្យ រិទ្ធីពល | ២៨- លោកវេជ្ជបណ្ឌិត | ជួង មេឃា |

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

| | | | |
|---|---|---|---|
| ១០- លោកវរសេនីយ៍ឯក | នួន សារី | ២៩- លោក | សឿន វឌ្ឍនា |
| ១១- លោក | សេង តារាវុឌ្ឍ | ៣០- លោក | មួង ឫទ្ធិ |
| ១២- លោក | ហែម សារិទ្ធ | ៣១- លោក | នួច សុជាតិ |
| ១៣- លោក | វង សារ៉ា | ៣២- ព្រះគ្រូយសលា | រិត ស៊ីធីម |
| ១៤- លោក | ហេង ចំណាប់ | ៣៣- លោក | ជួន ច័ន្ទរិទ្ធិ |
| ១៥- លោក | លី សារិនចាន់ណា | ៣៤- លោក | ខែ វណ្ណៈ |
| ១៦- លោក | នួន សុគន្ធី | ៣៥- លោក | ញ៉ាញ់ ញូន |
| ១៧- លោក | សុខ សារ៉ន្ត | ៣៦- លោក | ស្ងួ វីរៈ |
| ១៨- លោក | ឯម ឃា | ៣៧- លោក | ប៉ែន ចាន់ថន |
| ១៩- លោក | ជឹម វ៉ាន់ឌី | ៣៨- លោក | គុជ វណ្ណា |

ញ- គ្រឿងឥស្សរិយយស **មុន្នីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ :**

| | | | |
|---|---|---|---|
| ១- លោក | ស្វ សុវណ្ណដារ៉ា | ៣- លោក | នូ ជីវ័ន្ត |
| ២- លោក | គ្រួច សេងខួនហាក់ | ៤- លោក | សុផាន់ តារាវៀន |

ដ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **ធិបឌិន្ទ :**

| | | | |
|---|---|---|---|
| ១- លោក | តាំង ហាំងម៉េង | ២- លោក | សុខ លី |

ឋ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា :**

| | | | |
|---|---|---|---|
| ១- លោកវេជ្ជបណ្ឌិត | ថុង សុភាព | ១១- លោកវេជ្ជបណ្ឌិត | យ៉េង សុខន |
| ២- លោកវេជ្ជបណ្ឌិត | សែម ប៊ុនធឿន | ១២- លោកវេជ្ជបណ្ឌិត | តិច វែង |
| ៣- លោកវេជ្ជបណ្ឌិត | ប្រាក់ ស្រីរ៉ា | ១៣- លោកវេជ្ជបណ្ឌិត | ពេជ្រ ប៊ុនថន |
| ៤- លោកវេជ្ជបណ្ឌិត | សាត់ សាវុធ | ១៤- លោកវេជ្ជបណ្ឌិត | ស្រ៊ុន វុធដា |
| ៥- លោកវេជ្ជបណ្ឌិត | ឡុង ឡុងឌី | ១៥- លោកវេជ្ជបណ្ឌិត | អ៊ុច សុផាន់នី |
| ៦- លោកវេជ្ជបណ្ឌិត | គង់ ប្រាក់ | ១៦- លោក | នួន ចាន់ធឿន |
| ៧- លោកវេជ្ជបណ្ឌិត | សាន សុណ្ណ | ១៧- លោក | ស៊ុត ដារុម |
| ៨- លោក | មូល ម៉ាឡៃ | ១៨- លោក | វ៉ែន សារុន |
| ៩- លោក | នូ មន | ១៩- លោក | គុជ ម៉េងធូ |
| ១០- លោក | សួរ ជីវ័ន្ត | ២០- លោក | ស៊ុន ធឿន |

ឌ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ :**

| | | | |
|---|---|---|---|
| ១- លោកវេជ្ជបណ្ឌិត | ឃុន ចាន់សុគ័ន្ធ | ៨- លោកវេជ្ជបណ្ឌិត | អាយ គ្រី |
| ២- លោកវេជ្ជបណ្ឌិត | អៀន អាត | ៩- លោក | ស៊ុយ សុធី |
| ៣- លោកវរសេនីយ៍ត្រី | លី លាងគីម | ១០- លោក | ឆោម ប៊ូលីន |
| ៤- លោកអនុសេនីយ៍ឯក | លី លាងជូ | ១១- លោក | ម៉ី សុបញ្ញា |
| ៥- លោក | វណ្ណា ស៊ីនេ | ១២- លោក | លី សរ |
| ៦- លោក | គង់ សុវណ្ណារ៉ា | ១៣- លោក | សុខ ពុទ្ធី |
| ៧- លោក | វ៉ាន់ រតនា | ១៤- លោក | ផល ពិសិទ្ធ |

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៣៧៣.១៦០៧.០៧៥៣

លេខៈ ៦៧ ៥៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៤៥

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ  នរោត្តម  សីហមុនី**
**សមានភូមិជាតិសាសនា  រក្ខតខត្តិយា  ខេមរារដ្ឋរាស្ត្រ  ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា  សម្ពោហាភាស  កម្ពុជឯករាជរដ្ឋបូរណសន្តិ  សុភមង្គលា  សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ  ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី ៧
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំងនិងផ្តល់ឋានៈទីប្រឹក្សាឯកឧត្តម **អ៊ឹម  ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ឆៀ  ច័ន្ទសុគ័ន្ធ្រ** ជាទីប្រឹក្សា មានឋានៈស្មើ **រដ្ឋលេខាធិការ**

២- ឯកឧត្តម **ពេជ្រ  ឆាយ៉ា** ជាទីប្រឹក្សា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

**មាត្រា២ :** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម  និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ពរស.១៦០៧.៧៥៤

លេខ: ៧៤២ ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៦/៧៤៦

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៦/៦១៦ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៦ ស្តីពីការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី ៧
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ឯកឧត្តម **អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** បញ្ចប់មុខតំណែងឯកឧត្តម **ហេង រតនា** ពីជំនួយការសម្តេចព្រះមហិស្សរា **នរោត្តម ចន្ទ្រាពង្ស** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា២ :** តែងតាំងនិងផ្តល់ឋានៈឯកឧត្តម **ខឿក សុខាវិន** ជាជំនួយការសម្តេចព្រះមហិស្សរា **នរោត្តម ចន្ទ្រាពង្ស** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានឋានៈស្មើ **អគ្គនាយក** ។

**មាត្រា៣ :** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

៣៩៧.១៦០៧.៧៥៥

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខៈ ៧៤១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៦/៧៤៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦ )

**ប្រោសព្រះរាជទាន**

នូវ

គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា** :

**១- Mr. Zhan Jin Sheng General Manager of CRBC**

**២- Mr. Xiao Xinming General Manager of WACC**

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសំខាន់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ការ.១៦០៧.៧៥៦

លេខៈ ៧៤៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ៨ ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៦/៧៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៣៦ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំជាថ្មីនូវគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈអនុប្រធាន និងសមាជិក នៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ចំនួន ០៣ រូប :

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ឌឹម សុវណ្ណារុំ** | ជាអនុប្រធាន | មានឋានៈស្មើ **រដ្ឋលេខាធិការ** |
| ២- ឯកឧត្តម | **ជិន ម៉ាលីន** | ជាសមាជិក | មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៣- ឯកឧត្តម | **ខៀវ តុលា** | ជាសមាជិក | មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។ |

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ពរជ. ១៦០៩. ៧៥៧

លេខ: ៧៤៧ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ៨ ៧ ឆ្នាំ២០១៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៦/៧៤៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ  នរោត្តម  សីហមុនី**
**សមានភូមិជាតិសាសនា  រក្ខតខត្តិយា  ខេមរារដ្ឋរាស្ត្រ  ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា  សម្ភោហាគាស  កម្ពុជឯករាជរដ្ឋបូរណសន្តិ  សុភមង្គលា  សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ  ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៦

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈដល់លោកវេជ្ជបណ្ឌិតឯកទេស **ហ៊ុន ចំរើន** ជាសាស្ត្រាចារ្យមហាបរិញ្ញា នៅសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០១៦*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

ពរល. ១២០៧.៧៥៧

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខ: ៧៤៩ ស.ណ

**សំណៅចម្លងត្រឹមត្រូវតាមច្បាប់ដើម**

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ៖ ១៦៧ អនក្រ.បក**

# អនុក្រឹត្យ
# ស្តីពី
# ការកែសម្រួលមាត្រា៦ នៃអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស /រកត /០៩១៣ /៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា មួយ.–**

មាត្រា៦ នៃអនុក្រឹត្យលេខ៣២ អនក្រ.បក ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានធ្វើការកែសម្រួលដូចតទៅ÷

**មាត្រា៦ ថ្មី.–**

កម្រិតនៃការផ្ទេរធនធានពីថវិកាជាតិទៅក្នុងគណនីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់សម្រាប់ថេរៈវេលាចំនួនប្រាំ(០៥)ឆ្នាំលើមូលដ្ឋានក្របខ័ណ្ឌចំណាយរយៈពេលមធ្យមនៃថវិកាទូទៅរបស់រដ្ឋ។

កម្រិតនៃការផ្ទេរពីថវិកាជាតិទៅក្នុងគណនីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ឆ្នាំ២០១៦ដល់ឆ្នាំ២០២០ មានដូចខាងក្រោម ÷

- សម្រាប់ឆ្នាំថវិកា២០១៦មានចំនួន០,០២ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៥
- សម្រាប់ឆ្នាំថវិកា២០១៧មានចំនួន០,០៤ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៦
- សម្រាប់ឆ្នាំថវិកា២០១៨មានចំនួន០,០៥ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៧
- សម្រាប់ឆ្នាំថវិកា២០១៩មានចំនួន០,០៦ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៨
- សម្រាប់ឆ្នាំថវិកា២០២០មានចំនួន០,០៧ភាគរយនៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៩។

សម្រាប់ឆ្នាំ២០១៦ ធនធានដែលបានផ្ទេរពីថវិកាជាតិត្រូវបានប្រើប្រាស់ទាំងស្រុងសម្រាប់រ៉ាប់រងការចំណាយប្រតិបត្តិការរដ្ឋបាលទូទៅរបស់លេខាធិការដ្ឋានគ.ជ.ក។ ចាប់ពីឆ្នាំ២០១៧ដល់ឆ្នាំ២០២០

ការចំណាយសម្រាប់សមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅរបស់លេខាធិការដ្ឋានក.វ.កមិនត្រូវលើស ៣០ ភាគរយនៃធនធានដែលផ្ទេរពីថវិកាជាតិ។

កញ្ចប់ថវិកានៃមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាផ្នែកមួយនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំដែលត្រូវគ្រប់គ្រងផ្ទាល់ដោយក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ និងមានប្រធានក.វ.កជាអាណាប័ក។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបោះផ្សាយអាណត្តិផ្ទេរធនធានជាជំហានៗពីគណនីថវិកាជាតិទៅគណនីមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបើកនៅរតនាគារជាតិ។

**មាត្រាពីរ.–**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រាបី.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ និងសមាជិកក.វ.ក ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ៧ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **ទេសរដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** |
| **សម្ដេចក្រឡាហោម ស ខេង** | **បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន** |

**<u>កន្លែងទទួល ៖</u>**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រាបី*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៦៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## គ្រូពុទ្ធិកសិក្សានិងមន្ត្រីបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការបំពេញការងាររបស់មន្ត្រីសង្ឃនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនា។

**មាត្រា២ _**

អនុក្រឹត្យនេះមានគោលដៅកំណត់ការរៀបចំផែនការ គោលការណ៍និងលក្ខខណ្ឌនៃការជ្រើសរើស និងបច្ច័យនិច្ចកត្តសម្រាប់សេវាបង្រៀននិងការបំពេញការងាររបស់មន្ត្រីសង្ឃនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនា។

**មាត្រា៣ _**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះបេក្ខសមណៈ និង បេក្ខជនដែលប្រឡងជាគ្រូពុទ្ធិកសិក្សា គ្រូពុទ្ធិកសិក្សាជាបព្វជិត ព្រមទាំងមន្ត្រីសង្ឃដែលបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនា។

## ជំពូកទី២
## ការរៀបចំផែនការគ្រូពុទ្ធិកសិក្សានិងមន្ត្រីបំពេញការងារ នៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

**មាត្រា៤ _**

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ត្រូវរៀបចំផែនការគ្រូពុទ្ធិកសិក្សានិងមន្ត្រីបំពេញការងារដែលរួមមានគ្រូក្របខណ្ឌពុទ្ធិកសិក្សាជាគ្រហស្ថ គ្រូក្របខណ្ឌពុទ្ធិកសិក្សាជាបព្វជិត គ្រូជាប់កិច្ចសន្យាជាគ្រហស្ថ គ្រូជាប់កិច្ចសន្យាជាបព្វជិត មន្ត្រីរាជការក្របខណ្ឌ និងមន្ត្រីកិច្ចសន្យាបំពេញការងារនៅពុទ្ធិកសិក្សាផ្អែកលើសេចក្តីត្រូវការនៃការបណ្តុះបណ្តាល ប្រភេទមុខតំណែង អង្គភាព និងទីកន្លែងបំពេញការងារ។

សេចក្តីព្រាងផែនការនេះ ត្រូវដាក់ជូនក្រសួងធម្មការនិងសាសនា ដើម្បីពិនិត្យនិងដាក់បញ្ចូលក្នុងផែនការរួមនៃផែនការក្របខណ្ឌមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាប្រចាំឆ្នាំតាមនីតិវិធីជាធរមាន។

## ជំពូកទី៣
## គោលការណ៍និងលក្ខខណ្ឌនៃការជ្រើសរើសគ្រូពុទ្ធិកសិក្សា

**មាត្រា៥ _**

ការប្រឡងជ្រើសរើសគ្រូពុទ្ធិកសិក្សា ត្រូវអនុលោមតាមលក្ខខណ្ឌដូចគ្រូបង្រៀនគ្រប់កម្រិតនៃក្រសួងអប់រំ យុវជន និងកីឡានិងត្រូវអនុវត្តអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ អាចកំណត់លក្ខខណ្ឌបន្ថែមនៃការជ្រើសរើសផ្អែកលើសេចក្តីត្រូវការរបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

បេក្ខសមណៈនិងបេក្ខជនត្រូវមានអាយុមិនលើស៤៥(សែសិបប្រាំ)ឆ្នាំគិតត្រឹមថ្ងៃប្រឡង។

**មាត្រា៦ _**

ក្រសួងធម្មការនិងសាសនា ត្រូវចេញប្រកាសទទួលស្គាល់លទ្ធផលនៃការប្រឡងជ្រើសរើសបេក្ខសមណៈ និងបេក្ខជនដែលបានប្រឡងជាប់ស្លាពរជាគ្រូក្របខណ្ឌពុទ្ធិកសិក្សាតាមនីតិវិធីជាធរមាន។

បេក្ខសមណៈនិងបេក្ខជនដែលប្រឡងជាប់ស្លាពរជាគ្រូក្របខណ្ឌពុទ្ធិកសិក្សា ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលគរុកោសល្យដែលរៀបចំដោយអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។ រយៈពេលនៃការបណ្តុះបណ្តាលគរុ-កោសល្យ ត្រូវបានចាត់ទុកជារយៈពេលនៃការធ្វើកម្មសិក្សា។ ក្នុងករណីរយៈពេលបណ្តុះបណ្តាលគរុកោសល្យតិចជាង១២(ដប់ពីរ)ខែ គរុសមណសិស្ស-សិស្ស និងគរុសមណនិស្សិត-និស្សិត ត្រូវបំពេញកម្មសិក្សាបន្ថែមឱ្យគ្រប់រយៈពេល១២(ដប់ពីរ)ខែ ទើបអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ស្នើសុំការតាំងស៊ប់ទៅក្រសួងធម្មការនិងសាសនា អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

គរុសមណសិស្ស-និស្សិតដែលលាចាកសិក្ខាបទនឹងត្រូវបានតាំងស៊ប់ក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល។

**មាត្រា៧ _**

គរុសមណសិស្ស-និស្សិតដែលគង់នៅជាបព្វជិតហើយបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិឬនៅតាមគ្រឹះស្ថានពុទ្ធិកសិក្សា រាជរដ្ឋាភិបាលរក្សាទុកក្របខណ្ឌ ព្រមទាំងអតីតភាពការងារក្នុងមុខងារសាធារណៈ។

ករណីលាចាកសិក្ខាបទនៅពេលក្រោយ សាមីខ្លួននឹងត្រូវបានបញ្ចូលក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិល ដោយផ្តល់ជូនក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ដែលរាប់គិតចាប់ពីកាលបរិច្ឆេទនៃការតាំងស៊ប់រហូតដល់ថ្ងៃលាចាកសិក្ខាបទ ដោយមិនរំលឹកបច្ច័យនៃឋានន្តរស័ក្តិនិង/ឬថ្នាក់ឡើយ។ ចំពោះផលប្រយោជន៍នៃការចូលនិវត្តន៍ ត្រូវគិតផ្អែកលើអតីតភាពការងារដែលរាប់គិតចាប់ពីកាលបរិច្ឆេទនៃការដាក់ឱ្យធ្វើកម្មសិក្សារហូតដល់ថ្ងៃចូលនិវត្តន៍ អនុលោមតាមរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលជាធរមាន។

**មាត្រា៨ _**

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ត្រូវកំណត់និយាមនៃការផ្តល់សេវាបង្រៀនចំពោះគ្រូពុទ្ធិកសិក្សានិងគ្រូជាប់កិច្ចសន្យាសម្រាប់កម្រិតពុទ្ធិកសិក្សានីមួយៗ អនុលោមតាមនិយាមដែលកំពុងអនុវត្តក្នុងក្របខណ្ឌនៃក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងធម្មការនិងសាសនា ត្រូវផ្តល់ការគាំទ្រដល់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ក្នុងការគ្រប់គ្រងសេវាបង្រៀននៅតាមគ្រឹះស្ថានពុទ្ធិកសិក្សា ដើម្បីធានានូវប្រសិទ្ធភាពនិងគុណភាពនៃការបណ្តុះបណ្តាល។

## ជំពូកទី៤

## បច្ច័យនិច្ចភត្ត

**មាត្រា៩ _**

បច្ច័យនិច្ចភត្ត សំដៅយកប្រាក់ប្រចាំខែជាតម្លៃបច្ច័យដែលត្រូវបានបវារណាសម្រាប់មន្ត្រីសង្ឃបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ដូចខាងក្រោមៈ

| ល.រ. | បរិយាយ | បច្ច័យនិច្ចភត្ត(រៀល) |
|---|---|---|
| ១ | ព្រះអគ្គាធិការ<br>ព្រះសាកលវិទ្យាធិការ | ១ ៥០០ ០០០ |
| ២ | ព្រះអគ្គាធិការរង<br>ព្រះសាកលវិទ្យាធិការរង | ១ ៤២០ ០០០ |
| ៣ | ប្រធានផ្នែក<br>ព្រឹទ្ធបុរស<br>នាយកពុទ្ធិកមជ្ឈមណ្ឌលគរុកោសល្យ<br>ប្រធានសាខានៃពុទ្ធិកសាកលវិទ្យាល័យ | ១ ៣៩០ ០០០ |
| ៤ | អនុប្រធានផ្នែក<br>ព្រឹទ្ធបុរសរង<br>នាយករងពុទ្ធិកមជ្ឈមណ្ឌលគរុកោសល្យ<br>អនុប្រធានសាខានៃពុទ្ធិកសាកលវិទ្យាល័យ | ១ ៣៧០ ០០០ |

| ល.រ. | បរិយាយ | បច្ច័យនិច្ចភត្ត(រៀល) |
|---|---|---|
| ៥ | ប្រធានការិយាល័យ<br>ប្រធានលេខាធិការដ្ឋាន<br>ប្រធានដេប៉ាតេម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន<br>ប្រធានបណ្ណាល័យ | ១ ០៨០ ០០០ |
| ៦ | គ្រូក្របខណ្ឌពុទ្ធិកសិក្សាកម្រិតឧត្តម(បង្រៀននៅពុទ្ធិកសាកលវិទ្យាល័យ) | ១ ០៧០ ០០០ |
| ៧ | នាយកពុទ្ធិកមធ្យមសិក្សាទុតិយភូមិ(វិទ្យាល័យ) | ១ ០០០ ០០០ |
| ៨ | នាយករងពុទ្ធិកមធ្យមសិក្សាទុតិយភូមិ(វិទ្យាល័យ) | ៩៨០ ០០០ |
| ៩ | គ្រូក្របខណ្ឌពុទ្ធិកសិក្សាកម្រិតឧត្តម(បង្រៀននៅពុទ្ធិកមធ្យមសិក្សាទុតិយភូមិ) | ៩៧០ ០០០ |
| ១០ | អនុប្រធានការិយាល័យ<br>អនុប្រធានលេខាធិការដ្ឋាន<br>អនុប្រធានដេប៉ាតេម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន<br>អនុប្រធានបណ្ណាល័យ | ៩១០ ០០០ |
| ១១ | នាយកពុទ្ធិកមធ្យមសិក្សាបឋមភូមិ(អនុវិទ្យាល័យ) | ៩១០ ០០០ |
| ១២ | នាយករងពុទ្ធិកមធ្យមសិក្សាបឋមភូមិ(អនុវិទ្យាល័យ) | ៩០០ ០០០ |
| ១៣ | គ្រូក្របខណ្ឌពុទ្ធិកសិក្សាកម្រិតមូលដ្ឋាន(បង្រៀននៅពុទ្ធិកមធ្យមសិក្សាបឋមភូមិ) | ៨៩០ ០០០ |
| ១៤ | នាយកពុទ្ធិកបឋមសិក្សា | ៨៥០ ០០០ |
| ១៥ | នាយករងពុទ្ធិកបឋមសិក្សា | ៨៣០ ០០០ |
| ១៦ | គ្រូក្របខណ្ឌពុទ្ធិកសិក្សាកម្រិតបឋម(បង្រៀននៅពុទ្ធិកបឋមសិក្សា) | ៨១០ ០០០ |

គរុសមណសិស្ស-និស្សិត ត្រូវបានប្រគេនបច្ច័យនិច្ចភត្តផ្អែកលើកម្រិតនៃប្រភេទក្របខណ្ឌដែលបានប្រឡងជាប់។

បច្ច័យនិច្ចភត្តសម្រាប់មន្ត្រីសង្ឃបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិដូចមានកំណត់ខាងលើ ត្រូវរៀបចំប្រគេនមន្ត្រីសង្ឃតាមប្រព័ន្ធធនាគារគិតចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៦តទៅ ដោយមិនមានអានុភាពអនុវត្តប្រតិសកម្មឡើយ។

ការកែសម្រួលបច្ច័យនិច្ចភត្តសម្រាប់មន្ត្រីសង្ឃបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួងធម្មការនិងសាសនា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១០.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងធម្មការនិងសាសនា និងក្រសួងមុខងារសាធារណៈ ត្រូវសហការរៀបចំការបើកបច្ច័យនិច្ចភត្តដូចមានចែងក្នុងអនុក្រឹត្យនេះប្រគេនមន្ត្រីសង្ឃតាមប្រព័ន្ធធនាគារឱ្យបានទាន់ពេលវេលាដូចមន្ត្រីរាជការស៊ីវិល។

**មាត្រា១១ -**

មន្ត្រីសង្ឃដែលជាគ្រូក្របខណ្ឌពុទ្ធិកសិក្សាគង់នៅជាបព្វជិតរហូត ប៉ុន្តែមិនអាចបំពេញមុខងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិឬគ្រឹះស្ថានពុទ្ធិកសិក្សាបន្តទៀតបាន មន្ត្រីសង្ឃអង្គនោះនឹងត្រូវទទួលបានបច្ច័យនិច្ចកត្តផ្អែកលើអតីតភាពនៃការបង្រៀនកន្លងមកដូចខាងក្រោមៈ

- មានអតីតភាពបង្រៀនក្រោម២០(ម្ភៃ)ឆ្នាំ ទទួលបានបច្ច័យនិច្ចកត្តមួយលើកយ៉ាងតិចស្មើនឹងបច្ច័យនិច្ចកត្តចុងក្រោយគុណនឹង៤(បួន)និងមិនឱ្យលើសបច្ច័យនិច្ចកត្តចុងក្រោយគុណនឹង១០(ដប់) ដោយគណនាផ្អែកលើចំនួនឆ្នាំដែលបានបំពេញការងារ
- មានអតីតភាពបង្រៀនចាប់ពី២០(ម្ភៃ)ឆ្នាំ ដល់ក្រោម៣០(សាមសិប)ឆ្នាំ ទទួលបានបច្ច័យនិច្ចកត្តប្រចាំខែស្មើនឹង៦០(ហុកសិប)ភាគរយនៃបច្ច័យនិច្ចកត្តចុងក្រោយដោយគិតបន្ថែមពីរភាគរយក្នុងមួយឆ្នាំសម្រាប់អតីតភាពលើសពី២០(ម្ភៃ)ឆ្នាំ
- មានអតីតភាពបង្រៀនចាប់ពី៣០(សាមសិប)ឆ្នាំឡើងទៅ ទទួលបានបច្ច័យនិច្ចកត្តប្រចាំខែស្មើនឹង៨០(ប៉ែតសិប)ភាគរយនៃបច្ច័យនិច្ចកត្តចុងក្រោយ។

ក្រៅពីបច្ច័យនិច្ចកត្តផ្អែកលើអតីតភាពនៃការបង្រៀន មន្ត្រីសង្ឃខាងលើនឹងត្រូវទទួលបានរបបសន្តិសុខសង្គមផ្សេងទៀតពាក់ព័ន្ធនឹងសុខភាពនិងគ្រោះថ្នាក់ការងារដូចមន្ត្រីរាជការស៊ីវិល។

## ជំពូកទី៥
## បទប្បញ្ញត្តិដោយឡែក

**មាត្រា១២ -**

មន្ត្រីសង្ឃដែលជាគ្រូក្របខណ្ឌពុទ្ធិកសិក្សា ហើយមានមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ក្នុងករណីលាចាកសិក្ខាបទ ត្រូវរក្សាមុខតំណែងនៅដដែល ដោយរៀបចំបែបបទស្នើសុំតែងតាំងឡើងវិញ លើកលែងមុខតំណែងដែលបម្រុងទុកសម្រាប់តែបព្វជិត។

ព្រះសង្ឃមានមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនាដែលមិនមានក្របខណ្ឌ ក្នុងករណីលាចាកសិក្ខាបទ មិនរក្សាបានមុខតំណែងឡើយ។

ការតែងតាំងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនា ត្រូវអនុលោមតាមអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិនិងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១៣ -**

មន្ត្រីសង្ឃបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិនៃក្រសួងធម្មការនិងសាសនាដែលមានក្នុងពេលបច្ចុប្បន្ន ត្រូវរៀបចំគ្រប់គ្រងអនុលោមតាមគោលការណ៍ដែលមានកំណត់ក្នុងអនុក្រឹត្យនេះ។

គរុសមណសិស្ស-និស្សិតដែលបានប្រឡងជាប់ក្របខណ្ឌគ្រូពុទ្ធិកសិក្សាមុនអនុក្រឹត្យនេះចូលជាធរមាន ហើយនៅរក្សាភាពជាបព្វជិត ព្រមទាំងបាននិងកំពុងបង្រៀននៅគ្រឹះស្ថានពុទ្ធិកសិក្សាចាប់ពីកាលបរិច្ឆេទនៃការទទួលស្គាល់ក្របខណ្ឌដោយក្រសួងធម្មការនិងសាសនា នឹងត្រូវផ្តល់អតីតភាពការងារនិងអត្ថប្រយោជន៍ផ្សេងទៀតស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

ក្រសួងមុខងារសាធារណៈនិងក្រសួងធម្មការនិងសាសនា ត្រូវសហការរៀបចំគ្រប់គ្រងគ្រូក្របខណ្ឌពុទ្ធិកសិក្សាដែលបានប្រឡងជាប់កន្លងមកឱ្យបានរួចរាល់ក្នុងរយៈពេលយ៉ាងយូរ៣(បី)ខែក្រោយអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៤ .-**

ឧបសម្ព័ន្ធទី៣នៃអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

| ទេសរដ្ឋមន្ត្រី<br>រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា | ទេសរដ្ឋមន្ត្រី<br>/រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ |
|---|---|---|
| **ហ៊ឹម ឆែម** | **អូន ព័ន្ធមុនីរ័ត្ន** | **ពេជ្រ ប៊ុនធិន** |

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** ៖ ១៧៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៦ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨៣អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៣ ២៦៧ ០០០ ០០០ រៀល (បីប៊ីលានពីររយហុកសិបប្រាំពីរលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងការពារជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទូទាត់ប្រាក់បេសកកម្មទៅចូលរួមប្រជុំនៅបរទេស និងទទួលភ្ញៀវជាតិមកកម្ពុជា។

**មាត្រា៣._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៤០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

## សម្រេច

**មាត្រា ១.**-បំពាក់ **មេដាយស្ថាបនាជាតិ** ចំនួន ០៧គ្រឿង ជូនសប្បុរសជន ចំនួន ០៧រូប ដែលបានបរិច្ចាគថវិកា និងសម្ភារជួយឧត្ថម្ភដល់អង្គភាពតំបន់ប្រតិបត្តិការសឹករងកំពង់ធំ យោធភូមិភាគទី៤ កន្លងមក ដូចមានរាយនាមខាងក្រោមៈ

**ក-មេដាយមាសស្ថាបនាជាតិ**

- វរសេនីយ៍ត្រី **អ៊ូ សុធា** អត្តលេខ ០៨៩៦៧០ មេបញ្ជាការផ្នែកសឹករងសណ្តាន់ ថវិកា ១៨,២០០ ដុល្លារ

**ខ-មេដាយសំរិទ្ធស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១ | ឧកញ៉ា | **ចាន់ ភុគលន់** | ម្ចាស់រោងម៉ាស៊ីនកិនស្រូវក្រុងស្ទឹងសែន ថវិកា ១,១០០ ដុល្លារ |
| ២ | វរសេនីយ៍ទោ | **ថនស៊ី សត្ថា** | អត្តលេខ ០២៨៩៩៦ មេបញ្ជាការវរសេនាតូចលេខ១ ថវិកា ១,២៥៩ ដុល្លារ |
| ៣ | វរសេនីយ៍ទោ | **ចាន់ ខុម** | អត្តលេខ ០១៧៦៤៨ មេបញ្ជាការផ្នែកសឹករងបារាយណ៍ ថវិកា ១,១០០ ដុល្លារ |
| ៤ | វរសេនីយ៍ត្រី | **ឈុំ ឆៃ** | អត្តលេខ ០៦០៣១២ នាយសេនាធិការរង តំបន់ប្រតិបត្តិការសឹករងកំពង់ធំ ថវិកា ១,១០០ ដុល្លារ |
| ៥ | វរសេនីយ៍ត្រី | **ខេន ឈុនគរ** | អត្តលេខ ០៦០៤៥៧ អធិការស្រុកកំពង់ស្វាយ ថវិកា ១,១០០ ដុល្លារ |
| ៦ | វរសេនីយ៍ទោ | **ញៀម ឈុនលី** | អត្តលេខ០៤០០៦៤ អធិការស្រុកស្ទឹងសែន ថវិកា ១,១០០ ដុល្លារ |

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ មេបញ្ជាការកងទ័ពជើងគោក និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួលៈ**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៤១...អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយសហមេត្រី**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

**សម្រេច**

**មាត្រា ១.**-បំពាក់ **មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ** ចំនួន ០៣គ្រឿង ជូននាយទាហាននៃកងទ័ពប្រជាជនវៀតណាម ចំនួន ០៣រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គភាពតំបន់ប្រតិបត្តិការសឹករងកំពង់ធំ យោធភូមិភាគទី៤ នៃកងយោធពលខេមរភូមិន្ទ កន្លងមក ដូចមានរាយនាមខាងក្រោម៖

១-ឧត្តមសេនីយ៍ត្រី **រឿង វ៉ាន់ហាយ** RUOENG VAN HAY មេបញ្ជាការ ក្រុងហូជីមិញ កងទ័ពប្រជាជនវៀតណាម

២-វរសេនីយ៍ឯក **ត្រាន ង៉ុកខាយ** TRAN NGOK KHAY មេបញ្ជាការ ខេត្តដុងណាយ កងទ័ពប្រជាជនវៀតណាម

៣-វរសេនីយ៍ឯក **ង្វៀន គូកមិញ** NGVIENG KUK MIGN មេបញ្ជាការ ខេត្តប៊ិញភឿក កងទ័ពប្រជាជនវៀតណាម

**មាត្រា ២.**-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ មេបញ្ជាការកងទ័ពជើងគោក និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៥៤៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងទីប្រឹក្សាពាណិជ្ជកម្ម

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សម្រេច**

**មាត្រា ១** : បញ្ចប់អាណត្តិទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា នៅក្រៅប្រទេស ដូចខាងក្រោមៈ

១-លោក **ឡៅ ខុនអេង** ពីទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន

២-លោក **ទិត រិទ្ធិពល** ពីទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ

៣-លោកស្រី **កែវ មុត្តធីតា** ពីទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំសហរដ្ឋអាមេរិក

៤-លោក **វណ្ណា តារា** ពីទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម។

**មាត្រា ២** : តែងតាំងទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូត និងអមស្ថានបេសកកម្មអចិន្ត្រៃយ៍ព្រះរាជាណាចក្រកម្ពុជា នៅក្រៅប្រទេស ដូចខាងក្រោម៖

១-លោក **ញូង មណ្ឌល** ជាទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសជប៉ុន ជំនួសលោក **ឡៅ ខួនអេង**

២-លោក **យ៉ែម សុផល** ជាទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋកូរ៉េ ជំនួសលោក **ឆិត រិទ្ធិពល**

៣-លោក **ម៉ៅ សាគល** ជាទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ជំនួសលោកស្រី **កែវ មុត្តធីតា**

៤-លោក **ធួស សាផា** ជាទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម ជំនួសលោក **ទណ្ឌ តារា**

៥-លោក **យឹម សុខុម** ជាទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសអូស្ត្រាលី និងណូវែលហ្សេឡង់

៦-លោក **ឃឹម រ៉ូស្សាត** ជាទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំសហព័ន្ធរុស្ស៊ី

៧-លោក **សុខ ចំរើន** ជាទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានបេសកកម្មអចិន្ត្រៃយ៍កម្ពុជា នៅទីក្រុងហ្សឺណែវ

៨-លោកស្រី **ធុក មុជធារី** ជាទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំសហព័ន្ធម៉ាឡេស៊ី

៩-លោក **ជួន ចន្ទី** ជាទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំព្រះរាជាណាចក្របែលហ្សិក

១០-លោកស្រី **នួន ផានិត** ជាទីប្រឹក្សាពាណិជ្ជកម្ម អមស្ថានឯកអគ្គរាជទូតព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌូនេស៊ី។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨៤៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងមុខតំណែងមន្ត្រីនគរបាលជាតិកម្ពុជា

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥  ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា ១ :** តែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ទោ **អ៊ូ ម៉ានីរ៉ា** អគ្គលេខ ៧៨១០០ ជាអគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ។

**មាត្រា ២ :** បទប្បញ្ញត្តទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៤៤ អនក្រ.បក

## អនុក្រឹត្យ

## ស្ដីពី

## ការប្ដូរនិងតំឡើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០០ ស្ដីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** ប្ដូរនិងតំឡើងឋានន្តរស័ក្តិពីលេខាធិការរដ្ឋបាលថ្នាក់លេខ៩ មកឋានន្តរស័ក្តិនាយក្រមការ ថ្នាក់លេខ ៣ នៃក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងអភិវឌ្ឍន៍ជនបទជូន **លោក ខ៉ាន់ ថុល** ជាករណីពិសេស។

**មាត្រា ២.-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ [illegible] ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៤៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តែងតាំងលោកសាស្ត្រាចារ្យមហាបរិញ្ញា **សេង រស់សមិទ្ធិ** ជាព្រឹទ្ធបុរសមហាវិទ្យាល័យទន្តវេទសាស្ត្រ នៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល របស់ក្រសួងសុខាភិបាល ជំនួសលោកសាស្ត្រាចារ្យ **អ៊ឹម ពុធថាវ** ដែលបានសុំលាឈប់ពីការងារ ។

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ៧ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៤៦ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដាក់មន្ត្រីរាជការឱ្យចូលនិវត្តន៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការ និងសាសនា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់

ស្តីពីការបង្កើតក្រសួងផែនការ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និងសាសនា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់យុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** ដាក់មន្ត្រីរាជការចំនួន ៤៤ រូប របស់ក្រសួង ស្ថាប័នចំនួន ១៣ ឱ្យចូលនិវត្តន៍ក្នុងឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ឋានន្តរស័ក្តិគ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ នៃក្របខ័ណ្ឌគ្រូបង្រៀនកម្រិតឧត្តម ឋានន្តរស័ក្តិវរមន្ត្រី នៃក្របខ័ណ្ឌរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ និងឋានន្តរស័ក្តិមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ដូចមានរាយនាមខាងក្រោម ៖

| ល.រ | គោត្តនាម និងនាម | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ | ថ្ងៃខែឆ្នាំ ចូលនិវត្តន៍ |
|---|---|---|---|
| **១-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | | | |
| ១ | លោក **កឿន ភាន** | វរមន្ត្រី ថ្នាក់លេខ ៤ | ២០-សីហា-២០១៦ |
| **២-ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និង អធិការកិច្ច** | | | |
| ២ | លោក ម៉ម ណារ៉េន | វរមន្ត្រី ថ្នាក់លេខ ៤ | ០៨-កញ្ញា-២០១៦ |
| **៣-ក្រសួងពាណិជ្ជកម្ម** | | | |
| ៣ | លោក **សុប វ៉ា** | វរមន្ត្រី ថ្នាក់លេខ ២ | ០៣-កក្កដា-២០១៦ |
| ៤ | លោក **មើក នាង** | វរមន្ត្រី ថ្នាក់លេខ ១ | ០៩-កញ្ញា-២០១៦ |
| **៤-ក្រសួងធម្មការ និងសាសនា** | | | |
| ៥ | លោក **វ៉ាន់ សុទ្ធី** | វរមន្ត្រី ថ្នាក់លេខ ៣ | ០៥-កញ្ញា-២០១៦ |
| **៥-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | | | |
| ៦ | លោក **ជា ពិសិដ្ឋ** | វរមន្ត្រី ថ្នាក់លេខ ១ | ២០-កញ្ញា-២០១៦ |
| ៧ | លោក **នាក់ សារី** | វរមន្ត្រី ថ្នាក់លេខ ១ | ១៦-សីហា-២០១៦ |
| ៨ | លោក **ឯក ច័ន្ទសិរី** | វរមន្ត្រី ថ្នាក់លេខ ១ | ១៨-សីហា-២០១៦ |
| ៩ | លោក **ប៉ាង ងួន** | វរមន្ត្រី ថ្នាក់លេខ ៤ | ០១-សីហា-២០១៦ |
| ១០ | លោក **តែ ម៉េង** | វរមន្ត្រី ថ្នាក់លេខ ១ | ០១-កក្កដា-២០១៦ |
| ១១ | លោកស្រី **ទុង សុជាតិ** | វរមន្ត្រី ថ្នាក់លេខ ១ | ១០-សីហា-២០១៦ |
| ១២ | លោក **ស៊ុក គីមហេន** | វរមន្ត្រី ថ្នាក់លេខ ៣ | ០៩-កញ្ញា-២០១៦ |
| **៦-ក្រសួងអប់រំ យុវជន និង កីឡា** | | | |
| ១៣ | លោកស្រី **ជា ផល្លី** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ១៣-សីហា-២០១៦ |
| ១៤ | លោក **យិន សារឿន** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ០៤-កញ្ញា-២០១៦ |
| ១៥ | លោក **ទី សុខន** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ០១-សីហា-២០១៦ |
| ១៦ | លោក **ង៉ោ ប៊ុនរត្ន** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ២ | ២២-សីហា-២០១៦ |

| | | | |
|---|---|---|---|
| ១៧ | លោក **ជុំ ចាន់វិត្ថា** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ **២** | ០៣-កញ្ញា-២០១៦ |
| ១៨ | លោក **សយ ណារ៉ា** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ២៥-កញ្ញា-២០១៦ |
| ១៩ | លោក **អ៊ុម សុវណ្ណ** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ **២** | ៣០-កញ្ញា-២០១៦ |
| ២០ | លោក **សុខ ចំរើន** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ **២** | ១៤-កញ្ញា-២០១៦ |
| ២១ | លោកស្រី **ហ៊ុន ហារី** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ៣ | ២៧-សីហា-២០១៦ |
| ២២ | លោក **យុគ សុង** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ០១-សីហា-២០១៦ |
| ២៣ | លោក **ចាប សាឡន** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ១២-កក្កដា-២០១៦ |
| ២៤ | លោក **តាន់ និសៀង** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ ១ | ២១-សីហា-២០១៦ |
| ២៥ | លោក **ហ៊ី សាវុធ** | គ្រូបង្រៀនកម្រិតឧត្តមដើមខ្សែ ថ្នាក់លេខ **២** | ១៥-សីហា-២០១៦ |
| **៧-ក្រសួងសុខាភិបាល** | | | |
| ២៦ | លោក **ស៊ឹម យុទ្ធាសា** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ | ១៤-កក្កដា-២០១៦ |
| ២៧ | លោក **ឃុន សារ៉េត** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ **២** | ២៩-សីហា-២០១៦ |
| ២៨ | លោកស្រី **ទួន សុម៉ូនី** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ **២** | ០១-កក្កដា-២០១៦ |
| ២៩ | លោក **ហោ ឈឿង** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ | ៣០-សីហា-២០១៦ |
| ៣០ | លោក **ប៉ែន សំណាវិទ្ធ** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ | ១០-កញ្ញា-២០១៦ |
| ៣១ | លោក **តូច សុខុន** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ | ១១-សីហា-២០១៦ |
| ៣២ | លោក **ហ៊ិន គិមឃន** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ | ១០-កញ្ញា-២០១៦ |
| ៣៣ | លោកស្រី **យ៉ែម ម៉ាលីន** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ **២** | ០៥-សីហា-២០១៦ |
| ៣៤ | លោក **អៀវ គីរី** | មន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ **២** | ២០-សីហា-២០១៦ |
| **៨-ក្រសួងមហាផ្ទៃ** | | | |
| ៣៥ | លោក **អ៊ុក ឡាយ** | វរមន្ត្រី ថ្នាក់លេខ **២** | ១៥-កក្កដា-២០១៦ |
| ៣៦ | លោក **ចាន់ សារ៉ាត់** | វរមន្ត្រី ថ្នាក់លេខ ១ | ២៩-សីហា-២០១៦ |
| ៣៧ | លោក **គ្រួច សុខថុន** | វរមន្ត្រី ថ្នាក់លេខ ១ | ០១-កញ្ញា-២០១៦ |
| ៣៨ | លោកស្រី **ឈឹម ខេមា** | វរមន្ត្រី ថ្នាក់លេខ ១ | ០៩-សីហា-២០១៦ |
| ៣៩ | លោក **អ៊ឹង ប៊ុនអាង** | វរមន្ត្រី ថ្នាក់លេខ ១ | ១៧-កក្កដា-២០១៦ |
| **៩-ក្រសួងយុត្តិធម៌** | | | |
| ៤០ | លោកស្រី **សៅ ប៊ុននឿន** | វរមន្ត្រី ថ្នាក់លេខ **២** | ៣១-កក្កដា-២០១៦ |
| **១០-ក្រសួងផែនការ** | | | |
| ៤១ | លោកស្រី **វ៉ា ស៊ីនាង** | វរមន្ត្រី ថ្នាក់លេខ ៣ | ០៥-សីហា-២០១៦ |

| | | | |
|---|---|---|---|
| **១១-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍** | | | |
| ៤២ | លោក **មាស ចំរើន** | វរមន្ត្រី ថ្នាក់លេខ ៣ | ១៥-កញ្ញា-២០១៦ |
| **១២-ក្រសួងសាធារណការ និងដឹកជញ្ជូន** | | | |
| ៤៣ | លោក **អ៊ួ សំអុន** | វរមន្ត្រី ថ្នាក់លេខ ៣ | ០៦-សីហា-២០១៦ |
| **១៣-ក្រសួងអភិវឌ្ឍន៍ជនបទ** | | | |
| ៤៤ | លោក **ទីន ហៀសោល** | វរមន្ត្រី ថ្នាក់លេខ ១ | ២០-កក្កដា-២០១៦ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា "២"*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៩៤៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតម្លើងថ្នាក់ ឋានន្តរស័ក្តិ និងនិយ័តកម្មថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

# សម្រេច

**មាត្រា ១ .-** តម្លើងថ្នាក់ ឋានន្តរស័ក្តិប្រចាំឆ្នាំ និងនិយ័តកម្មថ្នាក់តាមអតីតភាពការងារ ជូនមន្ត្រីរាជការចំនួន ១០១ រូប នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងយុត្តិធម៌ ចាប់ពីថ្ងៃទី **១៣** ខែ **មេសា** ឆ្នាំ **២០១៦** ដូចមានរាយនាមខាងក្រោម ៖

**ក-តម្លើងថ្នាក់ និងឋានន្តរស័ក្តិប្រចាំឆ្នាំ**

| | | | |
|---|---|---|---|
| ១- | លោក **ម៉ាង ហឿន** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២- | លោក **លឹម សុគន្ធ** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៣- | លោក **ជូ ប៊ុនរីន** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៤- | លោក **ឡេង ស៊ុនណារិទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៥- | លោកស្រី **មុំ សុទ្ធារី** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៦- | លោក **ម៉ាន់ បូរេត** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៧- | លោកស្រី **ទៀង សំបូរ** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៨- | លោកស្រី **ម៉ុក វណ្ណា** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ៩- | លោក **ឃួន វ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១០- | លោកស្រី **ជុំ កន្និយ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១១- | លោកស្រី **អ៊ឹង ហុងធី** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១២- | លោក **ស្មួន រតនា** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៣- | លោក **ថ្លាង ភ្នំពេជ្រ** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៤- | លោក **ជា ចាន់ថា** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៥- | លោកស្រី **ឈាង ស៊ីណែត** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៦- | លោក **ប៉ែន ពេរ** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៧- | លោក **ឈិន ឡុង** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៨- | លោក **អ៊ុន ភាព** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៩- | លោក **កែវ ពិសុទ្ធ** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២០- | លោក **ប្រាក់ សឿន** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២១- | លោក **អំ សំអាត** | ពីវរមន្ត្រី ថ្នាក់លេខ **២** | មកវរមន្ត្រី ថ្នាក់លេខ ១ |

| | | | |
|---|---|---|---|
| ២២- | លោក **មៀច វុន** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២៣- | លោក **ចាយ វ័រ** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២៤- | លោក **វ៉ាន់ សេង** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២៥- | លោក **អែម ថា** | ពីវរមន្ត្រី ថ្នាក់លេខ ២ | មកវរមន្ត្រី ថ្នាក់លេខ ១ |
| ២៦- | លោក **សុខ តាំង** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៧- | លោក **ទូច ថារិទ្ធិ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៨- | លោក **សែម សុផាត** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ២៩- | លោក **ស៊ឹម ឧត្តម** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣០- | លោក **ឡេង សុភាព** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣១- | លោក **លី ទូច** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣២- | លោក **ប៉ោ សន្ធវ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៣- | លោក **ទឹម ឆេងឡុង** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៤- | លោក **សៀង ឆាវ៉ាត** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៥- | លោក **អោក លឹមចាន់រីណា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៦- | លោក **ហ្លួត ឈួរ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៧- | លោក **គ្រី គឹមឃាន់** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៨- | លោក **អ៊ុក វីរ៉ា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៣៩- | លោក **អ៊ុច សុខា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤០- | លោក **លី វ៉ាន់ហេង** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤១- | លោក **វុន សុជាតិ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤២- | លោក **កេត ណាង** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៣- | លោក **នៅ សុភាព** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៤- | លោក **សំ ថា** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៥- | លោក **យឺវ វណ្ណៈ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៦- | លោក **អ៊ុក រស្មី** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៧- | លោក **ហ៊ឹម ពុទ្ធាសុរិយៈ** | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |

| | | | |
|---|---|---|---|
| ៤៨- | លោក ឡុច សាមីឌី | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៤៩- | លោក ប៉ោ សុកនី | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៥០- | លោក ចេង មុនីរ័ត្ន | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៥១- | លោក ឃៀង សុមុនី | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៥២- | លោក ហេង ដូនីន | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៥៣- | លោក ស៊ិន វីរៈ | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៥៤- | លោក លឹម សុខន | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៥៥- | លោក ហេង សម្ផស្ស | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៥៦- | លោក ជូ ប៊ុនវ៉ា | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៥៧- | លោក កែវ ចិន្តា | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៥៨- | លោកស្រី ចាវ សុចាន់មុនី | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៥៩- | លោក សយ ចាន់នី | ពីវរមន្ត្រី ថ្នាក់លេខ ៣ | មកវរមន្ត្រី ថ្នាក់លេខ ២ |
| ៦០- | លោក គីម ថាវរ៉ូ | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦១- | លោក អ៊ុំ វ៉ន | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦២- | លោក សុខ ផលី | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៣- | លោក សុង ម៉ៅ | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៤- | លោក ឡេង វុធ | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៥- | លោក ប៊ុត សាវ៉ាត | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៦- | លោកស្រី ស្រេង សូឃ៉ែត | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៧- | លោកស្រី ប៊ិច ស៊ីហ៊ិន | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៨- | លោកស្រី ណុប សុធាវ៉ានី | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៦៩- | លោកស្រី អ៊ឹង កូលីណែត | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧០- | លោកស្រី ប៉េស រីណា | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧១- | លោក អ៊ា ណាគ្រី | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧២- | លោក ជៀប ឡុង | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧៣- | លោក ហ៊ី រតន៍ | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |

| | | | |
|---|---|---|---|
| ៧៤- | លោក ច័ន្ទ វ៉ាណារិទ្ធ | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧៥- | លោកស្រី ស៊ឹម សុផល្លា | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧៦- | លោកស្រី សារុន សាធី | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧៧- | លោក ហេង ម៉េងហួ | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧៨- | លោក អោក មានិត | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៧៩- | លោកស្រី ស៊ូ លក្ខិណា | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៨០- | លោក ហួយ វ៉ាន់ថន | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៨១- | លោក ស៊ុត ជារាម | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៨២- | លោក ជឹង ផេងស្រួយ | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៨៣- | លោក ច័ន្ទ សត្ថា | ពីវរមន្ត្រី ថ្នាក់លេខ ៤ | មកវរមន្ត្រី ថ្នាក់លេខ ៣ |
| ៨៤- | លោក ខៀវ សុខហួរ | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨៥- | លោកស្រី សុខុម ហ៊ុនពុទ្ធារី | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨៦- | លោក សេង សុធន | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨៧- | លោក យ៉េត រិទ្ធិយ៉ា | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨៨- | លោក នូ ឫទ្ធា | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៨៩- | លោកស្រី ឃឿន មុនីរស្មី | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩០- | លោកស្រី ឌុច សុខណៃ | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩១- | លោកស្រី ហេង លក្ខិណា | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩២- | លោក អ៊ី ស៊ីវន | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៣- | លោក ហួយ សេរីវឌ្ឍនពិសិដ្ឋ | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៤- | លោក ប៊ូ ឌីយ៉ាម៉ង្គម៉ារឌី | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៥- | លោក លី ចាន់ដារ៉ា | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៦- | លោក ឯក ថាវី | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៧- | លោក ពេជ្រ សុខប៊ូ | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៨- | លោក ឈិន ទេពិរុណ | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |
| ៩៩- | លោក រ៉ុត ចំណាន | ពីអនុមន្ត្រី ថ្នាក់លេខ ១ | មកវរមន្ត្រី ថ្នាក់លេខ ៤ |

១០០- លោក **វិរោចន៍ សុវណ្ណន៍** ពីអនុមន្ត្រី ថ្នាក់លេខ ១ មកវរមន្ត្រី ថ្នាក់លេខ ៤

**ខ-និយ័តកម្មថ្នាក់ តាមអតីតភាពការងារ**

១០១- លោក **កេត ស៊ីណេត** ពីវរមន្ត្រី ថ្នាក់លេខ ៤ មកវរមន្ត្រី ថ្នាក់លេខ ២

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៥៤៧ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំង និងប្រគល់ភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** តែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ចំនួន ១០ រូប របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដូចមានរាយនាមខាងក្រោម ៖

១- លោកស្រី **ម៉ូ ស៊ីថា** ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន ជំនួសលោក **អ៊ុំ សុផាន់ណារ៉ា** ដែលបានទទួលភារកិច្ចថ្មី

| | |
|---|---|
| ២- លោក **ឡៅ ម៉េង** | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ជំនួសលោក **រឿង រិទ្ធិរ័ត្ន** ដែលបានទទួលភារកិច្ចថ្មី |
| ៣- លោក **ឆុន ផលពិសិដ្ឋ** | ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ជំនួសលោក **ជួរ រតនៈ** ដែលបានទទួលភារកិច្ចថ្មី |
| ៤- លោក **យៀប ម៉ាលីណា** | ប្រគល់ភារកិច្ចឱ្យបំពេញមុខងារជា ប្រធាននាយកដ្ឋានសុខុមាលភាពជនពិការ ជំនួសលោក **ឡៅ វេង** ដែលបានទទួលភារកិច្ចថ្មី |
| ៥- លោក **ហែម អឿន** | ជានាយករង នៃវិទ្យាស្ថានជាតិសង្គមកិច្ច មានឋានៈស្មើអគ្គនាយករង |
| ៦- លោក **ខន្ធ តារៈ** | ជានាយករង នៃវិទ្យាស្ថានជាតិសង្គមកិច្ច មានឋានៈស្មើអគ្គនាយករង |
| ៧- លោក **សោម សំអឿន** | ជាអគ្គាធិការរង នៃអគ្គាធិការដ្ឋាន |
| ៨- លោក **ឡៀង ចិសាល** | ជាអធិការ នៃអគ្គាធិការដ្ឋាន ជំនួសលោកស្រី **ប៊ូ ស៊ីថា** ដែលបានទទួលភារកិច្ចថ្មី |
| ៩- លោក **គង់ សារិទ្ធ** | ជាអធិការ នៃអគ្គាធិការដ្ឋាន |
| ១០- លោក **យុត ចាន់ធី** | ប្រគល់ភារកិច្ចឱ្យបំពេញមុខងារជា អធិការ នៃអគ្គាធិការដ្ឋាន។ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សី៧ ឆ្នាំ ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧ សសរ

**សេចក្ដីសម្រេច**

**ស្ដីពី**

**ការតែងតាំងប្រធានក្រុមការងារថ្នាក់ជាតិ**
**ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី**
**នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលស្ដីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្ដីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្ដីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១._**

ត្រូវបានតែងតាំងលោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តស្វាយរៀង និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះ មូលដ្ឋានរាជធានីភ្នំពេញ។

**ប្រការ២._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលរាជធានីភ្នំពេញ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ   សាសនា   ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៧២៨...សសរ

**សេចក្ដីសម្រេច**
**ស្ដីពី**
**ការតែងតាំងប្រធានក្រុមការងារថ្នាក់ជាតិ**
**ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី**
**នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលស្ដីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្ដីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្ដីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.—**

ត្រូវបានតែងតាំងឯកឧត្តម **អ៊ី ឈាន** រដ្ឋលេខាធិការ ក្រសួងការពារជាតិ ជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តប៉ៃលិន។

**ប្រការ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តប៉ៃលិន និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ៧ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៧៥៩...សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការតែងតាំងអនុប្រធានក្រុមការងារថ្នាក់ជាតិ ចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធី នយោបាយនិងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យនិងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ ០១ សណន ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារចុះបំពេញបេសកកម្ម តាមមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១.**_

ត្រូវបានតែងតាំងឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាអនុប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តកំពង់ចាម។

**ប្រការ២.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាមី រដ្ឋបាលខេត្តកំពង់ចាម និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ៧ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៧០.សសរ**

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងសម្រាប់គាំទ្រគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងសាកល "Global Deal Initiative"

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញអនុក្រឹត្យលេខ២៨៣អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញសេចក្តីសម្រេចលេខ៥៨សសរ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងសម្រាប់គាំទ្រគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងសកល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .-**

ត្រូវបានកែសម្រួលសមាសភាពអនុប្រធានគណៈកម្មការអន្តរក្រសួងសម្រាប់គាំទ្រគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងសាកល "Global Deal Initiative" ពីឯកឧត្តម **អ៊ុច បូរិទ្ធ** រដ្ឋលេខាធិការ ទៅជាឯកឧត្តម **ជឹង ម៉ុនចេង** អនុរដ្ឋលេខាធិការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

**ប្រការ២ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការអន្តរក្រសួងសម្រាប់គាំទ្រគំនិតផ្តួចផ្តើមកិច្ចព្រមព្រៀងសកល ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ . ខែ សីហា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៣
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ   សាសនា   ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៨១ ស.ស.ម

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាសភាពគណៈកម្មាធិការជាតិជំរឿនទូទៅប្រជាជន នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៨ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ ស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង
